ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៣០

ចុះថ្ងៃទី២១ខែសីហាឆ្នាំ១៩៩៨

សាលដីកា

លេខ : ២៨

ចុះថ្ងៃទី១៦ខែកុម្ភៈឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ កុម្ភៈ - ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក រ៉ុប៊ិន ស៊ិន ជាចៅក្រម

៣- លោក វៀល មួន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ស៊ំ កេង ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោកស្រី យុត សុគន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១២៥ ចុះថ្ងៃទី៣០-០៣-៩៨ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៤៦៣ ចុះថ្ងៃទី ៣០-៧-៩៧ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សុខ គង់ អាយុ ៣៦ ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៥៦២ ក្រុម ៣០ ភូមិវ៉ែព្រែកតាគង់ ឃុំចាក់អង្រែលើ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ដូ ម៉ាច អាយុ ២៦ ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៥៦២ ក្រុម ៣០ ភូមិវ៉ែព្រែកតាគង់ ឃុំចាក់អង្រែលើ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះអ្នកស្រី ផាង សុភា អាយុ ៤២ ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ៥៦២ ក្រុម ៣០ ភូមិវ៉ែព្រែកតាគង់ ឃុំចាក់អង្រែលើ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

បានផ្ទេរសិទ្ធិអោយអ្នកស្រី សឹង សុវណ្ណគន្ធា ។

មានមេធាវីឈ្មោះ ស៊ូ ចាន់ធីរ៉ា

និងចុងបណ្តឹងសាទុក្ខឈ្មោះ ឌួង ទី អាយុ ៥០ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅ

ផ្ទះលេខ ៥៦២ ស្ទួន ក្រុម ៣០ ភូមិព្រែកតាគង់ ឃុំចាក់អង្រែលើ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មេធាវីលោក តី គិច ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំបើកផ្លូវចូលរោងសិប្បកម្មកែច្នៃដែក
-៤-១-១-

តាមបណ្តឹងសាទុក្ខលេខ ១១៥ ចុះថ្ងៃទី ២៦-៥-៩៨ របស់អ្នកស្រី សឹង សុវណ្ណតន្ទា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១២៥ ចុះថ្ងៃទី ៣០-០៣-៩៨ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៣០ ចុះថ្ងៃទី ២១-៨-៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៤-៨-៩៥ របស់ដើមចោទឈ្មោះ ឆួង ទី បានបញ្ជាក់ថា ដីដែរចូលរោងសិប្បកម្មរបស់ខ្លួននេះ ខ្លួនបានកាន់កាប់ និង ប្រើប្រាស់ជាកម្មសិទ្ធិជាយូរឆ្នាំមកហើយ ដោយមានសំអាងលិខិតស្នាមជាភស្តុតាងស្រាប់ ចុងចម្លើយបានមកសង់ផ្ទះបាំងលើផ្លូវនេះ ធ្វើអោយមានការផ្ទុះជំលោះការចេញ-ចូល សិប្បកម្មរបស់ខ្លួន ។

បានឃើញសាលក្រមលេខ ១៤១ "ខ" ចុះថ្ងៃទី២១-១១-៩៦ របស់ តុលាការក្រុង-ភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៤-៨-៩៥ របស់ដើមចោទឈ្មោះ ឆួង ទី ទុក-ជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- អោយឈ្មោះ សុខ គង់ , ជូ ម៉ាច , ផាង សុភា បង្កើតរោងបាំងចេញពីផ្លូវដោយទុកទទឹងផ្លូវប្រវែង ៤ ,៥ ម៉ែត្រ គិតពីចិញ្ចើមផ្លូវខាងត្បូងមក សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ។

៣- អោយឈ្មោះ សុខ គង់ ជូ ម៉ាច និងផាង សុភា រួមគ្នាបង់ប្រដាប់ក្តីតែពន្ធចុះបញ្ចាំក្តី និង ពន្ធតឹង ១.៨០០៛០០រង្វាន់ក្រុមប្រឹក្សាកាន់កាប់ប្រាក់ ២០០៛០០ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛០០ បូករួម ៧.០០០៛០០ ប្រាក់នេះកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបង់ទុករួចហើយ កាលបើផុតកំណត់បណ្តឹងឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០៛០០នេះទៅដើមចោទវិញ ។

៤- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវឧទ្ធរណ៍ និង បណ្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ សុខ គង់ , ជូ ម៉ាច , ផាង សុភា ប្តឹងតវ៉ាតាមបណ្តឹងចុះថ្ងៃទី៨-១២-៩៦ លើសាលក្រមកំបាំងមុខនេះ និង ស្នើសុំអោយតុលាការក្រុងភ្នំពេញបើកសវនាការជាថ្មីលើសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៦ ចុះថ្ងៃទី០៤-៦-៩៦ ។

បានឃើញសាលក្រមលេខ ៤៤ "ក" ចុះថ្ងៃទី ៣០-៤-៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :-

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៤-៨-៨៥ របស់ដើមចោទឈ្មោះ ឡុង ទី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយឃ្លាតនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងទាស់របស់ចុងចម្លើយចុះថ្ងៃទី ៥-១២-៨៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣-អោយឈ្មោះ ឡុង ទី បើកច្រកផ្លូវទទឹង ៤ម៉ែត្រតាមលំនាំចាស់ត្រង់ទៅរោងសិប្បកម្មកែច្នៃឈើរបស់ខ្លួន ស្ថិតនៅភូមិព្រែកអានង់ សង្កាត់ចាក់អង្រែលើ ក្រុងភ្នំពេញ ហើយបង្គាប់អោយឈ្មោះ ឡុង ទី ឧបត្ថម្ភប្រាក់ដល់គ្រួសារខាងលើការមេត្រីស្រុះស្រួល ។

៤-អោយឈ្មោះ សុខ គង់ , ស៊ូ ម៉ាច , និង ផាង សុភា រួមគ្នាបង់ប្រាក់ប្រដាប់ក្ដី គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធតែម ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីការទទួលប្រាក់២០០៛០០ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛០០ បូករួម ៧.០០០៛០០ ប្រាក់នេះកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយ ។

៥-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សាលក្រមនេះត្រូវបានឈ្មោះ ឡុង ទី ប្ដឹងឧទ្ធរណ៍តាមពាក្យបណ្ដឹងចុះថ្ងៃទី០២-៥-៨៧ ត្រង់ចំណុច នៃ សេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការលេខ១២៥ ចុះថ្ងៃទី៣០-៣-៨៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :-

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០២-០៥-៨៧ របស់ឈ្មោះ ឡុង ទី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-តម្កល់សាលក្រមលេខ ៤៤ "ក" -៣០-០៤-៨៧ លើកលែងតែចំណុចឧបត្ថម្ភប្រាក់ ក្នុងចំណុចទី៣ នៃ សាលក្រមត្រូវកំណត់អោយបានច្បាស់លាស់ថា :- បង្គាប់អោយឈ្មោះ ឡុង ទី ឧបត្ថម្ភប្រាក់ដល់ឈ្មោះ សុខ គង់ , ស៊ូ ម៉ាច និង ផាង សុភា ម្នាក់ៗចំនួន ៧០ម៉ឺនរៀល ។

៣.បង្គាប់អោយចុងចម្លើយរុះរោងចក្រ និង សំណង់ផ្សេងៗចេញពីផ្លូវដែលត្រូវបើក ចាប់ពីពេលសាលដីការនេះចូលជាស្ថាពរ ។

៤-បង្គាប់អោយឈ្មោះ ឡុង ទី បង់ប្រាក់ប្រដាប់ក្ដីជូនសាលាឧទ្ធរណ៍ចំនួន១៣.០០០៛០០ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធតែមចំនួន២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីការទទួលប្រាក់ចំនួន៤៥០៛០០ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛០០ និង ចំណាយលើអាគារតុលាការចំនួន ៥.០០០៛០០ ។ នៅពេលសាលដីការនេះចូលជាស្ថាពរ អោយបង់ពន្ធសមាមាត្រមួយភាគរយ នៃប្រាក់ដែលត្រូវបង់អោយចុងចម្លើយទាំងបីនាក់ ។ ប្រាក់ពន្ធសមាមាត្រនេះដាក់ចូលថវិការដ្ឋ ៨០ភាគរយ និងត្រូវបានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៥-សាលដីការនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដីបើកផ្លូវប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១១៥ ចុះថ្ងៃទី២៦-៥-៨៨ របស់អ្នកស្រី សឹង សុវណ្ណគន្ធា [illegible]

ក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី០៣-១០-៩៨ របស់អ្នកស្រី សឹង សុវណ្ណគន្ធា

បានឃើញសារណាតបរបស់លោក ឌួង ទី ចុះថ្ងៃទី ២៦-១០-៩៨

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:-សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីខាងលើនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី សឹង សុវណ្ណគន្ធា ដែលបានឆ្លើយនៅពេលសវនាការថា:- សាលាឧទ្ធរណ៍សំរេចមិនយុត្តិធម៌ ។ ឆ្នាំ ៧៩ គ្រួសារទាំងបីបានមកតាំងទីលំនៅពុកផ្លែងសព្វថ្ងៃនេះ ក្រោយមកមានប្រជាជន២គ្រួសារទៀតមកនៅខាងក្រោយ ដែលបច្ចុប្បន្នជារោងសិប្បកម្ម ថៅកែ ឌួង ទី នេះបានមកជួលដើម្បីពង្រីកផ្លូវ ២ម៉ែត្រ ២តឹកអោយមក ៤ម៉ែត្រដោយអោយ ១ខែ ៥០ដុល្លា តែគ្រួសារទាំងបីនេះមិនព្រម ឌួង ទី នេះពោលថានឹងយកអោយបាន បើយកមិនបានឈប់នៅចាក់អន្ទ្រេង គាត់ថាសំណង់នេះជាសំណង់អនាធិបតេយ្យ ដូច្នេះរោងសិប្បកម្មរបស់គាត់ ក៏អនាធិបតេយ្យដែរ ព្រោះស្ថិតនៅលើដីឡូតិ៍ជាមួយគ្នា ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឌួង ទី ដែលបានឆ្លើយនៅពេលសវនាការថា :- ខ្លួននិយាយជាការពិត ប្រជាជនធ្វើអ្វីក៏ដោយគឺត្រូវតែមានច្បាប់ តែគ្រួសារទាំង៣ធ្វើដោយគ្មានច្បាប់ៗ រោងចក្រសិប្បកម្មនេះមានតាំងពីសង្គមចាស់មកម្លេះ ។

លោក ជូ ចាន់ធីរ៉ា មេធាវីដើមបណ្តឹងសាទុក្ខបានធ្វើសេចក្តីសន្និដ្ឋានថា:- អ្នកស្រីគន្ធា និង គ្រួសារពីរទៀតពិតជាបានមករស់នៅតាំងពី១៩៧៩ តែ ឌួង ប្តី បង របស់ ឌួង ទី មករស់នៅ ឆ្នាំ ៨៣ គឺក្រោយដើមបណ្តឹងសាទុក្ខ ។ ដីផ្លូវនេះពីសង្គម ៤ម៉ែត្រមែនព្រោះមានម្ចាស់តែម្នាក់ តែក្រោយ៧៩ វាមានច្រើនគ្រួសារ ដូច្នេះគេទុកផ្លូវតែ ២ម៉ែត្រ ២តឹកទេ "ចំនួន៥គ្រួសារ" តែ ២គ្រួសារទៀតក្រោយមកក៏លក់អោយ ឌួង ប្តី ។ សង្កាត់បានធ្វើលិខិតបដិសេធលិខិតកាន់កាប់ដី តែ២គ្រួសារទេ ឯ១គ្រួសារទៀតមិនបានបដិសេធទេ ហើយលិខិតបដិសេធនោះបដិសេធខុសលេខបង្កាន់ដៃផលកសិកម្មស្រុកចេញអោយ ដូច្នេះការបដិសេធនេះវាគ្មានគតិយុត្តិទាល់តែសោះ ។

ពាក្យសំណង់អនាធិបតេយ្យ បានន័យថាសង់ទៅលើដីសាធារណៈ ឬ ដីរបស់អ្នកដទៃ ។

ការរស់នៅរបស់គ្រួសារទាំងបីគឺវាសមស្របទៅនឹងមាត្រា ៦២ និង ៧៤ នៃ ច្បាប់ ភូមិបាល ។

សូមឯកឧត្តមប្រធានមេត្តាបដិសេធសាលដីកាលេខ ១២៥ របស់ សាលាឧទ្ធរណ៍ និង សំរេចអោយបានយុត្តិធម៌ ។

លោក គី គិច មេធាវីចុងបណ្តឹងសាទុក្ខបានធ្វើសេចក្តីសន្និដ្ឋានថា:-

- ប្រាក់ ៧០ ម៉ឺនរៀលជាប្រាក់ឧបត្ថម្ភក្នុងនាមមនុស្សធម៌ មិនមែនទិញដីទេ ព្រោះ ដីនេះជាដីសាធារណៈ ។

- ផ្លូវនេះតូចមិនអាចបើកបរបានទេ

-សិប្បកម្មនេះគ្មានប៉ះពាល់ដល់បរិស្ថានទេ

-គ្មានការស៊ីចុតលុយរវាងលោក ទី និង សង្កាត់ទេ

-រោងចក្រនេះ មិនមែនទិញពីពីរនាក់នេះទេ គឺជារោងចក្រពីសង្គម ។

-បញ្ហាបង្កាន់ដៃគឺពេលដាក់ពាក្យសុំគេត្រូវតែចេញបង្កាន់ដៃអោយអក្ខាងហើយ ។

សូមឯកឧត្តមមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃ ភាគី.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ១១៥ ចុះថ្ងៃទី ២៦-៥-៩៨ របស់អ្នកស្រី សឹង សុវណ្ណគន្ធា តំណាងអោយលោក សុខ គង់ លោក ដុំ ម៉ាច និង អ្នកស្រី ផាង សុភា ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី ។

- យល់ឃើញថា អាជ្ញាធរ និង មន្ត្រីជំនាញខ័ណ្ឌមានជ័យ សុទ្ធតែបានទទួលស្គាល់ថាចុងចម្លើយទាំងបីនាក់ បានពង្រីកសំណង់អនាធិបតេយ្យ ធ្វើអោយច្រកផ្លូវតូចចង្អៀតខុសពីសភាពដើម ។

- យល់ឃើញថា អ្នកស្រី សឹង សុវណ្ណគន្ធា ដែលពុំបានប្តឹងឧទ្ធរណ៍ហើយបានប្តឹងសាទុក្ខពីការសំរេចរបស់សាលាឧទ្ធរណ៍ដែលបានសំរេចឧបត្ថម្ភប្រាក់មួយគ្រួសារ ៧០ម៉ឺនរៀល តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាបានឡើយ ពីព្រោះតុលាការកំពូលដែលជំនុំជំរះលើកទី១នេះ គឺជំនុំជំរះតែលើអង្គច្បាប់ មិនជំនុំជំរះលើអង្គសេចក្តីទេ ហើយបញ្ហាប្រាក់ឧបត្ថម្ភនេះពុំមែនជាមូលហេតុដែលបើកអោយតុលាការកំពូលទុកជាមោឃៈសាលដីកាសាលាឧទ្ធរណ៍បានតាមមាត្រា២០៩ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្ម-ទណ្ឌឡើយ ។ ម្យ៉ាងទៀតការបង្គាប់អោយចុងចម្លើយរុះរើសំណង់ចេញពីដីសាធារណៈជាគោល. ការណ៍ ចុងចម្លើយពុំត្រូវបានទទួលនូវតម្លៃតបស្នងអ្វីឡើយទេ ។

- យល់ឃើញថា ខ្លឹមសារសារណាចុះថ្ងៃទី ០៣-១០-៩៨របស់ អ្នកស្រី សឹង សុវណ្ណគន្ធា ដែលបានដាក់ជូនតុលាការកំពូល តុលាការជាន់ក្រោមបានពិចារណារួចនិងត្រឹមត្រូវហើយ ។

- ការដែលមេធាវីចុងចម្លើយអះអាងថាកូនក្តីលោកដែលបានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៧៩ មានសិទ្ធិលើដីនេះ តាមមាត្រា២ នៃ អនុក្រឹត្យលេខ ២៥ អនក្រ និង តាមមាត្រា ៦២ និង ៧៤ នៃ ច្បាប់ភូមិបាលនោះជាការភ័ន្តច្រឡំពីព្រោះថាមាត្រា៥ នៃ ច្បាប់ភូមិបាលកំណត់ថា ពុំអោយមានកម្មសិទ្ធិឯកជនលើដីសំរាប់ផ្លូវទេ ហើយចុងចម្លើយខ្លួនឯងក៏ទទួលស្គាល់ដែរថាច្រកល្ហងទ្វារ និង ផ្លូវនេះមានពីសង្គមចាស់ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១២៥ ចុះថ្ងៃទី ៣០-៣-៨៨ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ១១៥ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៨៨ របស់អ្នកស្រី សឹង សុវណ្ណគន្ធា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១២៥ ចុះថ្ងៃទី ៣០-៣-៨៨របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៨.០០០៛០០ ដែលលោក សុខ គង់ លោក ជូ ម៉ាច និង អ្នកស្រី ផាង សុភា បានបង់រួចហើយគឺ :-

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

បង្គាប់អោយលោក ឆួង ទី បង់ពន្ធសមាមាត្រតាមភាគរយលើចំនួនទឹកប្រាក់២.១០០.០០០៛,

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៨៩។